# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេប លេខពិសេស

ដូចដែលបានរាយការណ៍ជូនក្នុងការបោះពុម្ពផ្សាយលើកមុនរបស់ **<u>អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម</u>** ក្នុងថ្ងៃតែមួយនៃសវនាការលើកស្តុតាងក្នុងសំណុំរឿង០០២ វគ្គទី២ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** និងលោក **ខៀវ សំផន** បានធ្វើឲ្យកិច្ចដំណើរការនីតិវិធីសវនាការរបស់ អ.វ.ត.ក. លែងដំណើរការទៅមុខរួច ដោយសារតែពួកគេបានប្រកាសពីការសម្រេចចិត្តធ្វើពហិការមិនចូលរួមក្នុងសវនាការលើកនេះ។ មេធាវីការពារក្តីឲ្យសហជនជាប់ចោទទាំងពីរ បានរម្លឹកពីជំហរមិនកែប្រែរបស់ពួកគេថា នឹងមិនវិលត្រឡប់ចូលក្នុងបន្ទប់សវនាការវិញនោះទេ រហូតទាល់តែបញ្ហាជាក់ស្តែងនានាត្រូវបានដោះស្រាយ និងការស្នើសុំនានាក៏ត្រូវគោរពតាមការចង់បានផងដែរ។ ក្នុងអំឡុងពេលពីរសប្តាហ៍ចាប់តាំងពីការចាប់ផ្តើមធ្វើពហិការមក ទាំងអង្គជំនុំជម្រះសាលាដំបូង និងការិយាល័យសហព្រះរាជអាជ្ញា បានខិតខំព្យាយាមបង្ខំឲ្យក្រុមមេធាវីការពារក្តីវិលត្រឡប់ចូលក្នុងបន្ទប់សវនាការវិញ ដើម្បីបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ភាគីទាំងអស់ បានចាប់ផ្តើមលើកយកទាំងយុត្តិសាស្រ្តអន្តរជាតិ និងគោលការណ៍ណែនាំក្នុងស្រុក ស្តីពីនីតិវិធីរបស់ប្រទេសកម្ពុជា ដើម្បីធ្វើការសម្អាងហេតុផលលើទឡ្ហីករណ៍របស់ពួកគេរៀងៗខ្លួន ពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការធ្វើពហិការនេះ។

គម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI) បានកំពុងបោះពុម្ពផ្សាយនូវរបាយការណ៍ពិសេសស្តីពីការធ្វើពហិការនេះ ក្នុងគោលបំណងផ្តល់នូវការពិភាក្សាពិស្តារបន្ថែម អំពីបណ្តាច្បាប់អន្តរជាតិ និងវិធានគតិយុត្តនានាក្នុងស្រុក ដែលភាគីក្នុងកិច្ចដំណើរការនីតិវិធីសវនាការនេះបានយោងពាក់ព័ន្ធនឹងបញ្ហានេះ។ ផ្នែកទី២

នៃរបាយការណ៍នេះ រៀបរាប់បន្ថែមនូវសេចក្តីសង្ខេបមុនៗរបស់ **<u>អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម</u>** មុននៃការប្រកាសធ្វើពហិការនៅថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០១៤ ព្រមជាមួយនឹងសេចក្តីសង្ខេបស្តីពីការវិវឌ្ឍន៍នានា ក្នុងអំឡុងពេលពីរសប្តាហ៍ចុងក្រោយនេះ។ ផ្នែកនេះផងដែរ ក៏បានរៀបរាប់ពីបរិបទនីតិវិធីចំពោះការវិវឌ្ឍន៍ទាំងនេះ ដោយយោងទៅលើវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ហើយពាក់ព័ន្ធនឹងវិជ្ជាជីវៈរបស់មេធាវីការពារក្តី ដែលទាក់ទងនឹងបទដ្ឋាននានាដែលមានចែងក្នុងច្បាប់កម្ពុជា និងក្រមវិជ្ជាជីវៈមេធាវី។ ផ្នែកទី២នេះ ក៏ធ្វើការវិភាគផងដែរលើសំណុំរឿងជាច្រើនរបស់សាលាក្តីអន្តរជាតិនានា ដែលធ្លាប់បានធ្វើការដោះស្រាយនូវបញ្ហាដូចគ្នានេះ ស្តីពីភាពជាតំណាងរបស់មេធាវីការពារក្តី ការធ្វើពហិការមិនចូលរួមសវនាការ និងការប្តឹងដិតចិត្តចៅក្រម។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ធីឡូ ហ្គតត៍ស្គលក៍ (Thilo Gottschalk), ដាញៀល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា, ស្ទេហ្វានី តេ (Stephanie Teh), និង ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ អង្គការ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាង មជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu)និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣ មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានា ក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។